**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
**តុលាការរដ្ឋប្បវេណី**

# សាលក្រម

រឿងក្ដីលេខ ២៦៦ ប.អ.ស ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ២០២២
សញ្ញាណនៃរឿងក្ដី ៖ មិនអនុញ្ញាតឱ្យអនុវត្តបង្ខំនិងលុបចោលដីកាសម្រេច
ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ ថ្ងៃទី **៦** ខែ **តុលា** ឆ្នាំ **២០២២**
សាលក្រមលេខ **៣២"ញ"/ ២៩២**
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី **១៩** ខែ **តុលា** ឆ្នាំ **២០២២**

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

**ចៅក្រម**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

**ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ**

**ដើមចោទ**

ឈ្មោះ [redacted] **ចាន់សល្យ** ភេទស្រី កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ត្រូវជាម្ដាយរបស់ឈ្មោះ [redacted] អម្រឹត ភេទប្រុស កើតថ្ងៃទី០១ ខែធ្នូ ឆ្ន២០១២ និងឈ្មោះ [redacted] អមរា ភេទស្រី កើតថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៦

ដោយមានលោកមេធាវី [redacted] អត្តលេខ [redacted] មេធាវីសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីនៃ **ការិយាល័យមេធាវី** [redacted] តាំងនៅផ្ទះលេខ [redacted] ជា **មេធាវីតំណាងដោយអាណត្តិ** ។

**ចុងចម្លើយ**

ឈ្មោះ [redacted] **លឹម** ភេទស្រី កើតឆ្នាំ១៩៦១ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩ មានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ[redacted]

ដោយមានលោកមេធាវី [redacted] អត្តលេខ [redacted], លោកមេធាវី [redacted] អត្តលេខ [redacted] និងលោកមេធាវី [redacted] អត្តលេខ [redacted] មេធាវីសមាជិកគណៈមេធាវីនៃព្រះរាជា



Scanned with CamScanner

ណាចក្រកម្ពុជា ជាមេធាវីនៃ **ការិយាល័យមេធាវី** [redacted] តាំងនៅផ្ទះលេខ [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

### ១- ការទាមទាររបស់ដើមចោទ

**១-១** មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ។

**១-២** បង្គាប់ឱ្យលុបចោលដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ។

**១-៣** ឱ្យចុងចម្លើយសងសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០.០០០(មួយរយលាន) រៀល ឱ្យមកដើមចោទ ។

**១-៤** ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ចុងចម្លើយ ។

### ២- ការពន្យល់ត្រួសៗ នៃរឿងក្ដី

**២-១** ក្នុងរឿងក្ដីនេះ ដើមចោទបានសុំទាមទារមិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដោយសំអាងថាការចេញដីកាសម្រេច ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមចោទជាម្ដាយរបស់សន្តតិជនឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមា** ហើយចុងចម្លើយមានគំនិតទុច្ចរិត ចង់បានទ្រព្យរបស់មតកជនឈ្មោះ [redacted] **ចាន់ឌី** តែម្នាក់ឯង និងមានចេតនាបំភាន់ដល់តុលាការឲ្យចេញដីកាសម្រេច ទោះជាចុងចម្លើយបានដឹងថាមានសន្តតិជនឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមា** ដែលជាកូនបង្កើតរបស់មតកជនឈ្មោះ [redacted] **ចាន់ឌី** ។ ក្រៅពីនេះ ដើមចោទក៏បានសុំបង្គាប់ឲ្យលុបចោលដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប និងឲ្យចុងចម្លើយសងសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០.០០០(មួយរយលាន)រៀល ឲ្យមកដើមចោទ ផងដែរ ។

#### ២-២ ចំណុចវិវាទ

ក្នុងរឿងក្ដីនេះ មានចំណុចវិវាទ គឺ ៖

១- តើការទាមទាររបស់ដើមចោទ មិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប និងការទាមទាររបស់ដើមចោទឲ្យលុបចោលដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មានភាពត្រឹមត្រូវដែរឬទេ ?

២- តើភាគីដើមចោទ អាចទាមទារឲ្យភាគីចុងចម្លើយ សងសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០.០០០(មួយរយលាន)រៀល បានដែរឬទេ ?

### ៣- ការអះអាងរបស់គូភាគី

#### ៣-១ ការអះអាងរបស់ភាគីដើមចោទ

លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] បាន

ធ្វើសេចក្ដីថ្លែងការណ៍ដូចតទៅ៖ នៅក្នុងរឿងនេះ មានចំណុចវិវាទចំនួន២គឺ **ទី១-** តើការទាមទាររបស់ដើមចោទ មិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប និងការទាមទាររបស់ដើមចោទ ឲ្យលុបចោលដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មានភាពត្រឹមត្រូវដែរឬទេ ? និងទី២- តើភាគីដើមចោទអាចទាមទារឲ្យភាគីចុងចម្លើយ សងសំណងការខូចខាត និងជំងឺចិត្តចំនួន**១០០.០០០.០០០**(មួយរយលាន)រៀល បានដែរឬទេ?

**<u>ចំណុចវិវាទទី១</u>** ៖ នៅក្នុងរឿងនេះ ការទាមទាររបស់ដើមចោទមានភាពត្រឹមត្រូវ ដោយហេតុថាដើមចោទឈ្មោះ [redacted] **ចាន់សល្យ** មានទំនាក់ទំនងជាមួយឈ្មោះ [redacted] **ចាន់នី** នៅអំឡុងឆ្នាំ២០០៥ ជាអនីតិសង្វាស ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយលុះរហូតដល់ឆ្នាំ២០១២ ក៏មានកូនម្នាក់ឈ្មោះ [redacted] **អម្រឹត** ភេទប្រុស កើតនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១២ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៤/២០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ និងឆ្នាំ២០១៦ មានកូនម្នាក់ទៀតឈ្មោះ [redacted] **អមរា** ភេទស្រី កើតថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ មានសំបុត្របញ្ជាក់កំណើតលេខ ៣២៥ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ។ នៅក្នុងនេះដែរមានភស្ដុតាងជាសំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ផងដែរ ។ លុះនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ឈ្មោះ [redacted] **ចាន់នី** ជាឪពុករបស់កូនទាំងពីរបានទទួលមរណភាព ហើយដើមចោទបានដាក់ពាក្យសុំដើម្បីបែងចែកមត៌ក ដែលមាននៅក្នុងសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងលេខ **៦៦** ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ។ ចំពោះសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងនេះ ខ្លួនបានដាក់ឯកសារភស្ដុតាងនៅក្នុងសំណុំរឿងរួចហើយ ។ បន្ទាប់មកចៅក្រមទទួលបន្ទុក បានធ្វើនីតិវិធីហៅមកសាកសួរ ដូចមានក្នុងកំណត់ហេតុសាកសួរ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ហើយកំណត់ហេតុស្ដីពីការសាកសួរ ខ្លួនក៏បានដាក់ចូលជាភស្ដុតាងក្នុងសំណុំរឿងនេះផងដែរ ។ ស្រាប់តែនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ចុងចម្លើយបានដាក់ពាក្យសុំដីកាសម្រេចដោយឯកតោភាគី ដូចមានក្នុងសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងលេខ **១៤៦** ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដែលមានកម្មវត្ថុបណ្ដឹងសុំតុលាការ ចេញដីកាសម្រេច ៖

១- ទទួលស្គាល់ភាគីអ្នកដាក់ពាក្យសុំឈ្មោះ [redacted] **លីម** ឈ្មោះ [redacted] **ហ្សុីតា** ឈ្មោះ [redacted] **ហ្សុីណា** និងឈ្មោះ [redacted] **អូណា** ជាសន្តតិជនរបស់មតកជនឈ្មោះ [redacted] **ចាន់នី អ៊ែននី** ( [redacted] **ចាន់នី**) ។

២- ប្រគល់មត៌ករបស់មតកជនឈ្មោះ [redacted] **ចាន់ អ៊ែននី** ( [redacted] **ចាន់នី**) មានដីទំហំ **៥៧៥** ម៉ែត្រការ៉េ មានក្បាលដីលេខ **៤៣២០** មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-៤៣២០ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ មានទីតាំងស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដីទំហំ **២៥៥១**ម៉ែត្រការ៉េ មានក្បាលដីលេខ **៨៧៨២** មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-៨៧៨២ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០២០ មានទីតាំងស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប និងរថយន្តមួយគ្រឿង ម៉ាកFord ពាក់ផ្លាកលេខ **សៀមរាប 2A-7594** ឲ្យភាគីអ្នកដាក់ពាក្យសុំឈ្មោះ [redacted] **លីម** ជាម្ចាស់កម្មសិទ្ធិ ។

៣- ឱ្យភាគីអ្នកដាក់ពាក្យសុំទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។

បន្ទាប់មក សាលាដំបូងខេត្តសៀមរាប បានចេញដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ដោយបានសម្រេច ៖

១- ទទួលស្គាល់ភាគីអ្នកដាក់ពាក្យសុំឈ្មោះ [redacted] លីម ឈ្មោះ [redacted] ហ៊្សេីតា ឈ្មោះ [redacted] ហ៊្សេីណា និងឈ្មោះ [redacted] អូណា ជាសន្តតិជនរបស់មតកជនឈ្មោះ [redacted] ចាន់ឌី អ៊ែនឌី ( [redacted] ចាន់ឌី) ។

២- ប្រគល់មត៌ករបស់មកតជនឈ្មោះ [redacted] ចាន់ អ៊ែនឌី ( [redacted] ចាន់ឌី) មានដីទំហំ ៥៧៥ ម៉ែត្រការ៉េ មានក្បាលដីលេខ ៤៣២០ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-៤៣២០ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ មានទីតាំងស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដីទំហំ ២៤៥១ម៉ែត្រការ៉េ មានក្បាលដីលេខ ៨៧៨២ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-៨៧៨២ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ មានទីតាំងស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប និងរថយន្តមួយគ្រឿង ម៉ាកFord ពាក់ផ្លាកលេខ **សៀមរាប 2A-7594** ឲ្យសន្តតិជនឈ្មោះ [redacted] លីម ជាម្ចាស់កម្មសិទ្ធិ ។

៣- ឲ្យភាគីអ្នកដាក់ពាក្យសុំទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

ឃើញថា ការចេញដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ នេះ គឺធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន ដែលជាសន្តតិជនឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ដែលទ្រព្យសម្បត្តិដែលគាត់ស្នើសុំនេះ គឺជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] **ចាន់ឌី** ដែលជាមតកជន ដែលពួកគាត់ត្រូវទទួលមត៌ករបស់មតកជនឈ្មោះ [redacted] **ចាន់ឌី** ។ ហើយយើងពិនិត្យក្នុងរឿងនេះ ឃើញថា ចុងចម្លើយបានដឹងយ៉ាងច្បាស់ទ្រព្យសម្បត្តិដែលគាត់បានស្នើសុំទាំងអស់នេះ គឺមាននៅក្នុងសំណុំរឿងមុន គឺសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ៦៦ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប រួចហើយ ព្រមទាំងមានធ្វើកំណត់ហេតុសាកសួររបស់សាមីភាគីទាំងពីរទៀតផង មិនមែនគាត់មិនដឹងទេ ដោយកម្មវត្ថុដូចគ្នា ទ្រព្យសម្បត្តិដូចគ្នា ។ ប៉ុន្តែក្រោយពីគាត់បានកំណត់ហេតុសាកសួរហើយ គាត់បានដកឃ្លា ដោយគាត់មានគំនិតបំភាន់តុលាការ ឲ្យមានការភាន់ច្រឡំ ។ ខ្លួនអត់យល់ដែរ រឿងមានកម្មវត្ថុដូចគ្នាអ៊ីចឹងហើយ បែរជាដាក់ពាក្យសុំដោយមានកម្មវត្ថុដដែលយកតែម្នាក់ឯង ។ មួយវិញទៀត ទាក់ទងនឹងអង្គច្បាប់ គឺពាក់ព័ន្ធនឹងតតិយដែលមានផលប្រយោជន៍នៅក្នុងរឿងនេះ ហើយក្នុងមាត្រា **៣៦៥** កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថាតតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឲ្យអនុញ្ញាតការអនុវត្តដោយបង្ខំ ចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន ។ ក្នុងន័យនេះ តាមផ្លូវច្បាប់ ទទួលស្គាល់ថាតតិយជនដែលមានប្រយោជន៍ អាចដាក់ពាក្យប្តឹងសុំកុំឲ្យអនុញ្ញាតអនុវត្តដោយបង្ខំបាន ។ នៅក្នុងមាត្រា **១១៥៩** នៃក្រមរដ្ឋប្បវេណី បានចែងថាសន្តតិជនលំដាប់ទី១ កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនលំដាប់ទី១ ។ កូនរបស់មតកជន ទោះជាកូនបង្កើតក្តី កូនចិញ្ចឹមក្តី ត្រូវមានចំណែកស្មើៗគ្នា ។ ដូចយើងបានឃើញថា កូនរបស់មតកជន គឺគាត់ជាសន្តតិជន ច្បាប់តម្រូវឲ្យគាត់ត្រូវទទួលមត៌កពីមតកជនជាដាច់ខាត ។ ហេតុនេះ ផ្អែកលើហេតុផលទាំងអស់នេះ ឃើញថា ដើមចោទមានឯកសារបញ្ជាក់ថាកូននេះគឺជាកូនបង្កើតរបស់ឈ្មោះ [redacted] **ចាន់ឌី** ដោយមានសំបុត្របញ្ជាក់កំណើត មានសៀវភៅគ្រួសារ សំបុត្របញ្ជាក់កំណើតរបស់កូនទាំងពីរ ហើយនៅក្នុងសំបុត្របញ្ជាក់កំណើតពីមន្ទីរពេទ្យក៏មានដាក់ឈ្មោះ [redacted] **ចាន់ឌី** ជាឪពុកដែរ ។ អ៊ីចឹង ហេតុផលទាំងអស់នេះ បញ្ជាក់យ៉ាងច្បាស់ថាកូនទាំងពីរឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ពិតជាសន្តតិជនស្របច្បាប់ប្រាកដមែន ។ ហេតុនេះ ខ្លួនសំណូមពរស្នើសុំឲ្យតុលាការសម្រេចតាមការទាមទារដូចក្នុងកម្មវត្ថុបណ្តឹងរបស់ខ្លួន ។



Scanned with CamScanner

<u>ចំណុចវិភាគទី២</u>៖ ចំណុចនេះមានហេតុផលដែលដើមចោទអាចទាមទារបាន ដោយចុងចម្លើយបានដឹងហើយ សន្តតិជនរបស់មតកជនមានការប្តឹងផ្តល់គ្នា បែងចែកទ្រព្យសម្បត្តិដែលជាមត៌ក បែរជាគាត់មានចេតនាទុច្ចរិតចង់បានទ្រព្យតែម្នាក់ឯង ។ ដូច្នេះ កំហុសទាំងអស់នេះ គឺជាកំហុសរបស់ចុងចម្លើយទាំងស្រុង ។ ដូច្នេះ ស្នើសុំឲ្យលោកចៅក្រមសម្រេចតាមការទាម ទាររបស់ខ្លួន ។

លោកមេធាវី [redacted] សុំធ្វើសេចក្តីថ្លែងការណ៍បន្ថែមថាខ្លួនបានលើកឡើងកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ដោយយោងមាត្រា **៣៦៥** នៃក្រមនីតិវិធីរដ្ឋប្បវេណីថា តតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឲ្យអនុញ្ញាតអនុវត្តដោយបង្ខំបាន ។ ចំពោះការដាក់ពាក្យរបស់តតិយជនជាដើមចោទនេះ មានភស្តុតាង និងមានកូនជាសន្តតិជនរបស់មតកជនឈ្មោះ [redacted] **ចាន់នី** ។ ចំណុចមួយទៀត ការដាក់ពាក្យសុំដីកាសម្រេច ដែលមានដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ខ្លួនបានពិនិត្យទៅលើពាក្យសុំដីកាសម្រេចនេះហើយ ឃើញថាមានតែអ្នកដាក់ពាក្យសុំតែមួយប៉ុណ្ណោះ ដោយពុំមានភាគីម្ខាងទៀតនោះទេ ។ ទាក់ទងនឹងទម្រង់សុំមត៌ក គឺមានភាគីម្ខាងទៀត ជាចាំបាច់ ហើយការគ្រប់គ្រងមត៌ក ដែលពុំមានភាគីម្ខាងទៀតមានភាពត្រឹមត្រូវដែរឬទេ ? អ្វីដែលខ្លួនចង់បញ្ជាក់គឺថាកម្មវត្ថុបណ្តឹងដែលគាត់មានក្នុងដីកាសម្រេច គឺមានដូចគ្នាក្នុងកម្មវត្ថុនៃពាក្យសុំដីកាសម្រេច ដែលខ្លួនបានដាក់ពាក្យសុំដីកាសម្រេច ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ គឺដូចគ្នានឹងដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ ២០២២ ដូចគ្នានឹងពាក្យសុំដីកាសម្រេចដែលខ្លួនទាមទារទាំងស្រុងតែម្តង ។

ដើមចោទសុំឱ្យតុលាការពិនិត្យភស្តុតាងជាឯកសារដូចខាងក្រោម ៖

១- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៤ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ (ចំនួន០១សន្លឹក ថតចម្លង) ។

២- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៥ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ (ចំនួន០១សន្លឹក ថតចម្លង) ។

៣- លិខិតបញ្ជាក់កំណើតលេខ ១៤៩៩ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ របស់មន្ទីរពេទ្យជ័យវរ្ម័នទី៧ ផ្នែកសម្ភព (ចំនួន០១សន្លឹក ថតចម្លង) ។

៤- សៀវភៅស្នាក់នៅលេខ ២៧១/០៩ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៩ (ចំនួន០១សន្លឹក ថតចម្លង) ។

៥- ពាក្យសុំដីកាសម្រេចរបស់ឈ្មោះ [redacted] ចាន់សល្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៩ (ចំនួន០១សន្លឹក ថតចម្លង) ។

៦- កំណត់ហេតុសាកសួរភាគី ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] អម្រឹត (ចំនួន០២សន្លឹក ថតចម្លង) ។

៧- ពាក្យសុំដីកាសម្រេចរបស់ឈ្មោះ [redacted] លឹម ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ (ចំនួន០៦សន្លឹក ថតចម្លង) ។



Scanned with CamScanner

៨- ដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប (ចំនួន០៥សន្លឹក ថតចម្លង) ។

៩- សៀវភៅគ្រួសារលេខ ១៦ ទំព័រ ៣០៣១ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **ចាន់នី** (ចំនួន០២សន្លឹក ថតចម្លង) ។

១០- សៀវភៅស្នាក់នៅលេខ ២៨៦.០១២ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ (ចំនួន០១សន្លឹក ថតមច្លង) ។

១១- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៨០០៩០៩១៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] **ចាន់នី** (ចំនួន០១សន្លឹក ថតចម្លង) ។

១២- សំបុត្របញ្ជាក់កំណើតលេខ ២១២ សៀវភៅបញ្ជាក់កំណើតលេខ០៣/២០១២ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **ចាន់នី អេិននី** (ចំនួន០១សន្លឹក ថតចម្លង) ។

១៣- លិខិតបញ្ជាក់អត្តសញ្ញាណលេខ ១០៦៥ សសដ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ចៅសង្កាត់ស្វាយដង្គំ (ចំនួន០១សន្លឹក ថតចម្លង) ។

១៤- សំបុត្រអាពាហ៍ពិពាហ៍លេខ ១២២ សៀវភៅអាពាហ៍ពិពាហ៍លេខ ០៣/២០២១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ (ចំនួន០១សន្លឹក ថតចម្លង) ។

១៥- សេចក្ដីចម្លងសំបុត្រមរណភាព ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលសំបុត្រមរណភាពលេខ ១៤៣ សៀវភៅមរណភាពលេខ ០៦/២០២១ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] **ចាន់នី អេិននី** (ចំនួន០១សន្លឹក ថតចម្លង) ។

១៦- សេចក្ដីសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ២១៣ សៀវភៅបញ្ជាក់កំណើតលេខ ០៣/២០១២ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **លីម** (ចំនួន០១សន្លឹក ថតចម្លង) ។

១៧- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៨០៤០៧២១០ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] **លីម** (ចំនួន០១សន្លឹក ថតចម្លង) ។

១៨- សំបុត្របញ្ជាក់កំណើតលេខ ២១៤ សៀវភៅបញ្ជាក់កំណើតលេខ ០៣/២០១២ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **ហ៊្សីតា** (ចំនួន០១ច្បាប់ ថតចម្លង) ។

១៩- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៨០៩៥៩៩៧៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **ហ៊្សីតា** (ចំនួន០១សន្លឹក ថតចម្លង) ។

២០- សំបុត្របញ្ជាក់កំណើតលេខ ២១៥ សៀវភៅបញ្ជាក់កំណើតលេខ ០៣/២០១២ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **ហ៊្សីណា** (ចំនួន០១សន្លឹក ថតចម្លង) ។

២១- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៨០៩៨០០៨០ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **ហ៊្សីណា** (ចំនួន០១សន្លឹក ថតចម្លង) ។

២២- សំបុត្របញ្ជាក់កំណើតលេខ ២៩២ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០១២ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **អូណា** (ចំនួន០១ច្បាប់ ថតចម្លង) ។

២៣- លិខិតបញ្ជាក់ទាយាទ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ចៅសង្កាត់ស្វាយដង្គំ (ចំនួន

០១សន្លឹក ថតចម្លង) ។

២៤- លិខិតបញ្ជាក់ស្តីពីការអនុញ្ញាត ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ហ៊្សីតា (ចំនួន០១សន្លឹក ថតចម្លង) ។

២៥- លិខិតបញ្ជាក់ស្តីពីការអនុញ្ញាត ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ហ៊្សីណា (ចំនួន០១សន្លឹក ថតចម្លង) ។

២៦- សំបុត្រអនុញ្ញាតពីក្រុមប្រឹក្សាញាតិ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ចេញដោយចៅសង្កាត់ស្វាយដង្គំ (ចំនួន០១សន្លឹក ថតចម្លង) ។

២៧- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-៤៣២០ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប (ចំនួន០១សន្លឹក ថតចម្លង) ។

២៨- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-៨៧៨២ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប (ចំនួន០១សន្លឹក ថតចម្លង) ។

២៩- ប័ណ្ណសម្គាល់រថយន្តមួយគ្រឿង ម៉ាក FORD ពាក់ផ្លាកលេខ **សៀមរាប 2A-7594** (ចំនួន០១សន្លឹក ថតចម្លង) ។

## ៣-២ ការអះអាងរបស់ភាគីចុងចម្លើយ

លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបថា ៖

**I. ការឆ្លើយតបចំពោះខ្លឹមសារនៃការទាមទាររបស់ដើមចោទ**

មិនទទួលស្គាល់នូវការទាមទាររបស់ដើមចោទក្នុងពាក្យបណ្តឹង ដែលចុះនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ទាំងស្រុង ដោយមូលហេតុថា ៖

*១-* ការប្តឹងទាមទារចំណុចទី១ ដែលប្តឹងមិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប នោះការប្តឹងនេះគឺ ៖

- ធ្វើឲ្យមានការប៉ះពាល់ដល់ទំនាក់ទំនងសិទ្ធិស្របច្បាប់របស់ចុងចម្លើយ ដែលមានក្នុងសេចក្តីសម្រេចទាំងមូល ។ ព្រោះក្នុងសេចក្តីសម្រេចនេះ គឺ មានការសម្រេចផ្សេងៗទៀតដែលមិនមានការទាក់ទងទៅនឹង **ដើមចោទ** នោះទេ ។
- ភាគីកូនរបស់ដើមចោទឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ដែលតំណាងដោយ **ដើមចោទ** នោះ គឺពុំមានសិទ្ធិផ្លូវច្បាប់ ដែលទទួលស្គាល់ឈ្មោះ [redacted] **អម្រឹត** និង [redacted] **អមរា** ជាសន្តតិជន របស់មតកជនឈ្មោះ [redacted] **ចាន់ឌី អេីន ឌី** ([redacted] **ចាន់ឌី**) ដើម្បីក្លាយខ្លួនជាអ្នកមានមូលដ្ឋាន *<u>មានសិទ្ធិក្នុងការប្តឹងជាតតិយជនក្នុងរឿងអនុវត្តដីកាសម្រេចនេះឡើយ</u>*។
- ចំពោះការលើកឡើងរបស់ដើមចោទដែលសំអាងទៅលើសំបុត្របញ្ជាក់កំណើតលេខ ៣២៤ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] **អម្រឹត** និងសំបុត្របញ្ជាក់កំណើត



Scanned with CamScanner

លេខ ៣២៥ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] អមរា សំបុត្រកំណើតនេះ ថ្វី ត្បិតតែបានដាក់ឈ្មោះឪពុកឈ្មោះ [redacted] ចាន់នី អ៊ើននី ([redacted] ចាន់នី) ក៏ពិតមែន តែ សំបុត្រនេះ គឺទៅចុះក្រោយពីឈ្មោះ [redacted] ចាន់នី អ៊ើន នី([redacted] ចាន់នី) _បានស្លាប់បាត់បង់ទៅ_ (មិនមែនឈ្មោះ [redacted] ចាន់នី អ៊ើន នី [redacted] ចាន់នី ជាអ្នកចុះនោះទេ) ដូច្នេះ សំបុត្រនេះ ***មិនមានអានុភាពទទួលស្គាល់*** ថា ជាកូនរបស់ឈ្មោះ [redacted] ចាន់នី អ៊ើននី ([redacted] ចាន់នី) នោះឡើយ ។

- ការចុះសំបុត្រកំណើត របស់ឈ្មោះ [redacted] អម្រឹត និងឈ្មោះ [redacted] អមរា និងបានដាក់ឈ្មោះ [redacted] ចាន់នី ជាឪពុកនោះ គឺភាគី **ដើមចោទ** ជាអ្នកចុះដោយខ្លួនឯងទេ គ្មានការទទួលស្គាល់ពីឈ្មោះ [redacted] ចាន់នី នោះទេ ។
- ការចុះសំបុត្រកំណើតនេះ មិនត្រឹមត្រូវទៅតាមទម្រង់ច្បាប់នោះទេ (ព្រោះគ្មានចុះហត្ថលេខា ឬផ្តិតមេដៃទទួលស្គាល់ពីឈ្មោះ [redacted] ចាន់នី ) វាផ្ទុយនឹងមាត្រា ៩៩៨ នៃក្រមរដ្ឋប្បវេណី ។ ហេតុនេះ សំបុត្រកំណើតនេះគ្មានអនុភាពក្នុងការទទួលស្គាល់ឈ្មោះ [redacted] អម្រឹត និងឈ្មោះ [redacted] អមរា ជាសន្តតិជនរបស់មតកជនឈ្មោះ [redacted] ចាន់នី នោះឡើយ ព្រោះអ្នកទាំងពីរនេះមិនមែនជាកូនក្នុងបន្ទុកនៃក្រុមគ្រួសារស្របច្បាប់ ដូចភាគី**ចុងចម្លើយ** ជាមួយឈ្មោះ [redacted] ចាន់នី នោះទេ ។
- តាមបញ្ញត្តិច្បាប់មាត្រា ៩៩៣ ដល់មាត្រា ១០០១ នៃក្រមរដ្ឋប្បវេណី គឺបានកំណត់អំពីការទទួលស្គាល់ជាកូន តែផ្ទុយមកវិញភាគីខាង**ដើមចោទ** គឺមិនមានទម្រង់ណាមួយតាមច្បាប់ដែលត្រូវទទួលស្គាល់ឈ្មោះ [redacted] អម្រឹត និងឈ្មោះ [redacted] អមរា ជាកូនរបស់មតកជនឈ្មោះ [redacted] ចាន់នី នោះឡើយ ។
- សរុបសេចក្តីមក ដើមចោទមិនមានសិទ្ធិជាកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតតាមផ្លូវច្បាប់ ដែលរាំងស្ទះក្នុងការអនុវត្តដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តសៀមរាបនេះទេ ។

២- ការប្តឹងទាមទារចំណុចទី២ ដែលប្តឹងបង្គាប់ឲ្យលុបចោលដីកាសម្រេចលេខ **២៥៧/**២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាបនោះ ការប្តឹងនេះមិនត្រឹមត្រូវតាមច្បាប់នោះទេ ព្រោះថា ៖

- ដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប គឺជាការសម្រេចអំពីទំនាក់ទំនងសិទ្ធិជាផ្លូវច្បាប់និងប្រយោជន៍ស្របច្បាប់ និងចំណងទាក់ទងរបស់ **ចុងចម្លើយជាមួយកូនបង្កើតរបស់ខ្លួន** ដែលមានការពាក់ព័ន្ធនឹងមតកជនឈ្មោះ [redacted] ចាន់នី អ៊ើននី តែប៉ុណ្ណោះ ។
- ដីកាសម្រេចនេះ តាមច្បាប់ គឺមានតែភាគីក្នុងដីកាសម្រេចនេះទេ ដែលមានសិទ្ធិសុំលុបបាន ដោយឡែកតតិយជនមិនមានសិទ្ធិមកធ្វើការប្តឹងលុបដីកានេះបានឡើយ ។

៣- ការប្តឹងទាមទារចំណុចទី៣ ដែលប្តឹងឲ្យចុងចម្លើយសងសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០.០០០(មួយរយលាន)រៀល ឲ្យមកដើមចោទនោះ ការប្តឹងនេះមិនត្រឹមត្រូវតាមច្បាប់

នោះទេ ព្រោះថា ៖

- រឿងនេះ គឺដើមចោទជាអ្នកប្តឹងចុងចម្លើយដោយគ្មានមូលដ្ឋានច្បាប់ ។
- ចុងចម្លើយមិនមានទំនាក់ទំនង សិទ្ធិនិងកាតព្វកិច្ច ក្នុងការទទួលខុសត្រូវណាមួយជាមួយភាគីដើមចោទនោះទេ ។ ជាមួយគ្នានេះដែរ ដើមចោទក៏មិនបានធ្វើការរំលោភសិទ្ធិណាមួយទៅលើដើមចោទនោះដែរ ។
- គ្មានហេតុផល ឬអំពើរបស់ចុងចម្លើយខុសច្បាប់ណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់ដើមចោទនោះទេ ។ ផ្ទុយមកវិញ ដើមចោទទេ ដែលបានប្តឹងចុងចម្លើយ ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់ចុងចម្លើយ និងធ្វើឲ្យចុងចម្លើយខាតបង់ពេលវេលា និងប្រាក់កាស់ក្នុងការចំណាយក្នុងរឿងនេះ ។
- មិនដឹងថា ដើមចោទខូចខាតទៅលើអ្វីខ្លះ ដែលមានទំហំរហូតដល់ ១០០.០០.០០០ រៀលនោះ? តែបើមានការខូចខាតក៏ដោយ ក៏មិនមែនជាបន្ទុករបស់ចុងចម្លើយដែរ ។

សរុបសេចក្តីមក គ្មានមូលដ្ឋានផ្លូវច្បាប់ដែលតម្រូវឲ្យចុងចម្លើយសងដើមចោទ ដូចការទាមទារនេះទេ ។

៤- ការប្តឹងទាមទារចំណុចទី៤ ដែលប្តឹងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយនោះ ការប្តឹងនេះ មិនត្រូវតាមច្បាប់នោះទេ ព្រោះថារឿងនេះ ចុងចម្លើយមិនមែនជាអ្នកមានកំហុសក្នុងរឿងនេះ ដើមចោទទេដែលបានប្រព្រឹត្តសកម្មភាពប្តឹងដោយខុសច្បាប់ ។

**II. ការឆ្លើយតបចំពោះខ្លឹមសារនៃអង្គហេតុដែលអះអាងរបស់ដើមចោទ**

**ក- <u>អង្គហេតុដែលទទួលស្គាល់</u>**

- ទទួលស្គាល់ថាមានអង្គហេតុថាដើមចោទបានដាក់ពាក្យសុំដែលមានសំណុំរឿងក្តីរដ្ឋប្បវេណី មិនមែនបណ្តឹងលេខ ៦៦ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ។
- ទទួលស្គាល់អង្គហេតុថា ឈ្មោះ [redacted] **ចាន់នី** បានទទួលមរណភាពនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ។
- ទទួលស្គាល់អង្គហេតុថាចុងចម្លើយបានដាក់ពាក្យសុំ ដែលមានសំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹងលេខ ១៤៦ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២២ ។ តាមពាក្យសុំនេះ តុលាការបានចេញដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ។

**ខ- <u>អង្គហេតុដែលមិនទទួលស្គាល់</u>**

- មិនទទួលស្គាល់អង្គហេតុដែលថា ដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ បានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន ដែលជាសន្តតិជនដែលត្រូវបានទទួលចំណែកមត៌ករបស់មតកជនឈ្មោះ [redacted] **ចាន់នី** តាមច្បាប់ដាច់ខាត ។
- មិនទទួលស្គាល់នូវការលើកឡើងរបស់ដើមចោទដែលបានចោទថា ចុងចម្លើយមានគំនិតទុច្ចរិត ដែលចង់បានផលប្រយោជន៍របស់មតកជនឈ្មោះ [redacted] **ចាន់នី** ( [redacted] **នី**) តែម្នាក់ឯង ។
- មិនទទួលស្គាល់ចុងចម្លើយ បានដឹងថាឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ដែលជាកូនបង្កើតរបស់មតកជន ឈ្មោះ [redacted] **ចាន់នី**( [redacted] **នី**) ។



Scanned with CamScanner

- ផ្ទុយមកវិញ ជាការពិត ចុងចម្លើយមិនបានដឹង ហើយក៏មិនបានទទួលស្គាល់ដូចការអះអាងនេះដែរ ហើយជាការពិត ការមិនទទួលស្គាល់នេះហើយ ទើបកើតមានការប្តឹងរបស់**ដើមចោទ** ដូចបានលើកឡើងខាងលើ ។

**III. ការអះអាងរបស់ចុងចម្លើយ**

ចុងចម្លើយឈ្មោះ [redacted] **លីម** និងឈ្មោះ [redacted] **ចាន់នី អេនឌី** បានរៀបការជាមួយគ្នា **តាមប្រពៃណី** នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៨៧ និងក្នុងការរួមរស់ជាមួយគ្នាចាប់ពីបានគ្នាជាប្តីប្រពន្ធមកគឺមានកូនចំនួន ០៣នាក់ មានឈ្មោះ ៖

១- ឈ្មោះ [redacted] **ហ្ស៊ីតា** ភេទប្រុស កើតឆ្នាំ ១៩៨៨ មានសំបុត្របញ្ជាក់កំណើតលេខ ២១៤ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ នៅអគ្រានុកូលដ្ឋានសង្កាត់ ស្វាយដង្គំ ក្រុងសៀមរាប ។

២- ឈ្មោះ [redacted] **ហ្ស៊ីណា** ភេទប្រុស កើតឆ្នាំ១៩៩៣ មានសំបុត្របញ្ជាក់កំណើតលេខ ២១៥ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ នៅអគ្រានុកូលដ្ឋានសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ។

៣- ឈ្មោះ [redacted] **អូណា** ភេទស្រី កើតឆ្នាំ ២០០៨ មានសំបុត្របញ្ជាក់កំណើតលេខៈ ២៩២ ចុះថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ២០១២ នៅអគ្រានុកូលដ្ឋានសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ។

ក្នុងជីវភាពនៃការរស់នៅក្នុងឆ្នាំ២០១២ ក្រុមគ្រួសារខ្លួនបានមករស់នៅខេត្តសៀមរាប នៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប (ដូចមានបញ្ជាក់ក្នុងសៀវភៅគ្រួសារលេខ ១៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២) និងបានធ្វើការចុះសំបុត្តអាពាហ៍ពិពាហ៍ នៅមន្ត្រីអាត្រនុកូលដ្ឋានសង្កាត់ស្វាយដង្គំលេខ **១២២** ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ។ ក្នុងជីវភាពនៃការរួមរស់នៅជាមួយគ្នា ខ្លួននិងប្តី មានទ្រព្យរួម គឺ ៖

- ដីទំហំ ៥៧៥ម² មានក្បាលដីលេខ **៤៣២០** មានវិញ្ញាបនបត្រសម្គាល់ម្ចាស់ អចលនទ្រព្យលេខ 17100602-4320 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ។
- ដីទំហំ ២៤៥១ម² មានក្បាលដីលេខ **៨៧៨២** មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យលេខ 17100602-8782 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០២០ ។
- តូបផ្សារចំនួន ០២តូប នៅក្នុងផ្សារដើមក្រឡាញ់ ខេត្តសៀមរាប ។
- រថយន្តមួយគ្រឿង ម៉ាក FORD ពាក់ផ្លាកលេខ សៀមរាប 2A-7594 ។

បន្ទាប់ពីប្តីខ្លួនឈ្មោះ [redacted] **ចាន់នី** បានទទួលមរណភាព នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមិនមានបណ្តាំទៅ ស្រាប់តែភាគី **ដើមចោទ** ចេញមកអះអាងថា គាត់មានកូនជាមួយប្តីខ្លួនឈ្មោះ [redacted] **ចាន់នី** និងបានប្តឹងសុំឲ្យទទួលស្គាល់កូននោះ*ជាសន្តតិជន*របស់ឈ្មោះ [redacted] **ចាន់នី** និងប្តឹងសុំបែងចែកមត៌កដូចនៅក្នុងពាក្យសុំដីកាសម្រេច របស់ភាគី**ដើមចោទ** តាមពាក្យសុំ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ ដែលបានប្តឹងសុំ ៖

១- សុំឲ្យទទួលស្គាល់ឈ្មោះ [redacted] **អម្រឹត** ភេទប្រុស កើតថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១២ និងឈ្មោះ [redacted] **មករា** ភេទស្រី កើតថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ជាសន្តតិជន របស់មតកជន ឈ្មោះ [redacted] **ចាន់នី** ។

២- សុំបែងចែកមត៌កដោយឡែករបស់មតកជន ឈ្មោះ [redacted] **ចាន់នី** តាមច្បាប់ឲ្យទៅសន្តតិជន ។



Scanned with CamScanner

៥. សំបុត្របញ្ជាក់កំណើត លេខ ២១៥ ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២ ។

៦. សំបុត្របញ្ជាក់កំណើត លេខ ២៩២ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១២ ។

៧. លិខិតបញ្ជាក់ទាយាទ លេខ ២១២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ។

- លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបបន្តថានៅក្នុងរឿងនេះពាក់ព័ន្ធនឹងលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយមានចំណុចវិវាទ ទី១-តើការទាមទាររបស់ដើមចោទមិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប និងការទាមទាររបស់ដើមចោទឲ្យលុបចោលដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មានភាពត្រឹមត្រូវដែរឬទេ? អ៊ីចឹងដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប សូមលោកចៅក្រមពិចារណា ដោយនៅក្នុងដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មានសម្រេចថា ១. ទទួលស្គាល់អ្នកដាក់ពាក្យសុំប្រពន្ធ និងកូនជាសន្តតិជនរបស់មតកជន ២. ការចាត់ចែងទៅលើទ្រព្យ និង៣. ការសម្រេចទៅលើប្រាក់ប្រដាប់ក្តី ។ អ៊ីចឹងផ្ទុយមកវិញ សួរថាចំណុចដែលប្តឹងទាមទារនៅក្នុងពាក្យបណ្តឹង មានភាពត្រឹមត្រូវដែរឬទេ? អ៊ីចឹងបើខ្លួនស្តាប់មិនច្រឡំទេ ក្នុងពេលសវនាការពេលនេះ ខ្លួនពិនិត្យឃើញថាពេលខ្លះពាក់ព័ន្ធនឹងដីកាសម្រេច ហើយបែរជាលើកហេតុផលពីភាពមិនត្រឹមត្រូវពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ។ បើពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ហេតុអ្វីប្តឹងទៅលើដីកាសម្រេចទាំងមូល ? អ៊ីចឹង ខ្លួនសុំលើកឡើងមួយចំណុចពាក់ព័ន្ធនឹងខាងគាត់បានលើកឡើង ពាក់ព័ន្ធនឹងសិទ្ធិ តើមានត្រឹមត្រូវ ឬមិនត្រឹមត្រូវ? អ៊ីចឹងពាក្យថា ត្រឹមត្រូវ ក្នុងលទ្ធផលនៃនីតិវិធីត្រៀមហ្នឹង ត្រឹមត្រូវឬយ៉ាងណា? ទី១.ទាក់ទងនឹងផ្លូវច្បាប់ ទី២.ទាក់ទងនឹងសិទ្ធិថា គាត់មានសិទ្ធិឬអត់? អ៊ីចឹងខ្លួនសុំនិយាយពីសិទ្ធិរបស់គាត់ យើងដឹងហើយថាអង្គហេតុ ភាគីខាងចុងចម្លើយទទួលស្គាល់ទំនាក់ទំនងផ្លូវការរវាងមតកជនដែលបានស្លាប់ រហូតដល់មានកូន២នាក់ មិនមែនមិនដឹងទេ តែជាការអះអាងរបស់គាត់ ។ អ៊ីចឹងសួរថាផ្លូវច្បាប់ បើសិនមិនមែនជាបន្ទុកស្របច្បាប់ ច្បាប់តម្រូវឲ្យធ្វើយ៉ាងម៉េចដើម្បីទទួលថាជាកូន? អ៊ីចឹងបានច្បាប់ចាប់ពីមាត្រា ៩៩៣ រហូតដល់១០០១ នៃក្រមរដ្ឋប្បវេណី បានកំណត់ឲ្យធ្វើនីតិវិធីតាមហ្នឹង ។ មិនមែនទៅចុះសំបុត្រកំណើតខ្លួនឯងហើយថាជាកូននោះទេ មិនបានទេ ។ អ៊ីចឹងបានចំណុចនេះ ដូចសហភាគាបានលើកឡើងមិនទទួលស្គាល់កូនដោយសារអ៊ីចឹង ។ ប្រសិនបើមានដីកាសម្រេចរបស់តុលាការ តាមនីតិវិធី ប្រហែលអាចខាងចុងចម្លើយអាចទទួលស្គាល់តែនេះមិនមានទេ ។ បើនិយាយពីភាពត្រឹមត្រូវ គិតខ្លួនឯងហើយ បញ្ហាផ្លូវច្បាប់ដែលភាគីដើមចោទបានលើកឡើងដោយយកសំអាងលើមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ អ៊ីចឹងក្នុងមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងនីតិវិធីបាននិយាយពីការអនុវត្តដោយបង្ខំ ដែលតតិយជនដែលមានការពាក់ព័ន្ធ យកមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី មកប្តឹង ។ អ៊ីចឹងមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់យ៉ាងច្បាស់ហើយអំពីលិខិតទាំងឡាយដែលត្រូវអនុវត្តដោយបង្ខំនោះ ក្នុងនោះអត់មានដីកាសម្រេចនោះទេ ។ អ៊ីចឹងសួរថាដីកាសម្រេចអាចអនុវត្តតាមមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានដែរឬទេ ? វាអត់មាននិយាយ? ដូច្នេះហើយតាមផ្លូវច្បាប់ភាគីបានលើកសំអាងទៅលើមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនអាចអនុវត្តបានទេ ។ គាត់មិនមានសិទ្ធិប្តឹងទេ ។ អ៊ីចឹងខ្លួនឃើញក្នុងមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី និយាយបញ្ជាក់យ៉ាងច្បាស់ថា តតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុ

ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្ដឹងតវ៉ា ។ អ៊ីចឹងក្នុងនេះគឺជាប្រភេទពាក្យបណ្ដឹងតវ៉ា ។ អ៊ីចឹងខ្លួនសួរមកវិញថាសិទ្ធិរបស់គាត់ទាក់ទងនឹងកម្មសិទ្ធិ គាត់មានអ្វីបញ្ជាក់ថាគាត់មានអត្ថិភាពនៃសិទ្ធិ។ ចំពោះគាត់លើកឡើងថាជាកូនមិនទាន់មានសិទ្ធិទេ ហើយការបញ្ជាក់អត្ថិភាពនៃកម្មសិទ្ធិ មានអ្វីមកបញ្ជាក់ អះអាងពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិ ។ នេះគឺជាចំណុចទី១ ដែលខ្លួនលើកឡើងប្ដឹងមិនអនុញ្ញាតឲ្យអនុវត្តទៅលើដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ។ អ៊ីចឹងគាត់មិនអាចប្ដឹងដីកាសម្រេចទាំងមូលអ៊ីចឹងបាននោះទេ ។ ខ្លួនសុំលើកឡើងទៅចុះ បង្ហាញលោកចៅក្រម បើគាត់សុំមិនអនុញ្ញាតមួយចំណុចបាន ប៉ុន្តែគាត់សុំមិនឲ្យអនុវត្តដីកាសម្រេចទាំងមូល ។ មិនតែប៉ុណ្ណោះ ចំណុចទី២ទៀត ប្ដឹងសុំលុបដីកាសម្រេចតែម្ដង សួរថានីតិវិធីនៃការលុបដីកាសម្រេច ច្បាប់បានចែងច្បាស់ណាស់ អ្នកណាមានសិទ្ធិលុបលើដីកានោះ មិនមែនតតិយជនមានសិទ្ធិទាមទារលុបដីកាសម្រេចនេះបាននោះទេ ព្រោះនេះជាការសម្រេចរបស់ភាគីពីរផ្សេងពីគ្នាដោយឡែក ។ មួយទៀតគាត់បានលើកឡើងថាគាត់មានសិទ្ធិ និងសំអាងថាមានភាពត្រឹមត្រូវ ដោយថាភាគីខាងចុងចម្លើយបានទៅដាក់ពាក្យសុំដីកាសម្រេចមួយទៀត ដោយមានបណ្ដឹងសុំរួចទៅហើយ ។ អ៊ីចឹងលោកចៅក្រមពិចារណាថាអ្វីដែលភាគីចុងចម្លើយ គាត់ប្ដឹងរឿងផ្សេងហ្នឹង អាចជាមូលហេតុ អាចជាភាពត្រឹមត្រូវសម្រាប់គាត់ដែរអត់? នេះគឺជាភាពត្រឹមត្រូវសម្រាប់គាត់ ហើយនេះគឺជាការប្ដឹងផ្សេងដោយឡែកពីគ្នា ។ ដីកាសម្រេចនេះពាក់ព័ន្ធនឹងសិទ្ធិបណ្ដឹងតវ៉ា ត្រូវយកអ្នកទទួលបានទ្រព្យជាចុងចម្លើយ ហើយដីកាសម្រេចនេះ គាត់ជាតតិយជនពុំសិទ្ធិនោះទេ ។ ចំណុចវិវាទទី២ លុបចោលដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ខ្លួនសុំសង្កត់ធ្ងន់ថាការលុបចដីកាសម្រេចនេះ នីតិវិធីច្បាប់បានកំណត់ច្បាស់ហើយ កំណត់អ្នកមានសិទ្ធិលុបយ៉ាងម៉េច? ចំណុចវិវាទទី៣ ពាក់ព័ន្ធនឹងសំណងចំនួន ១០០.០០០,០០០(មួយរយលាន) រៀល ។ សួរថាពាក់ព័ន្ធនឹងរឿងនេះការទាមទារសំណងខូចខាតនេះ ដោយផ្អែកលើអ្វី? ការទាមទារសំណងទី១. លើជនបង្កកំហុស ហើយក្នុងរឿងនេះ សួរថាភាគីដើមចោទឬភាគីចុងចម្លើយជាអ្នកបង្កកំហុស។ អ៊ីចឹងហើយ អ្នកមានកំហុស និងគ្មានកំហុស ដូចការលើកឡើងក្នុងឯកសារចម្លើយរួចហើយ ។ ចំណុចមួយទៀត ការទាមទារចំនួន **១០០.០០០.០០០**(មួយរយលាន)រៀល មានឯកសារណាបញ្ជាក់អត់? គាត់ចេះតែទាមទារមានភស្តុតាងអ្វីបញ្ជាក់អត់ មានវិក័យបត្រអត់ គាត់ចេះតែទាមទារ ។ មួយវិញទៀត ពាក់ព័ន្ធនឹងការបញ្ជាក់អត្ថិភាពនៃសិទ្ធិក្នុងការទាមទារ ឃើញថាដើមចោទពុំមានសិទ្ធិនោះទេ ហើយគាត់យកកូនជាលេសប៉ុណ្ណោះ ។ ចំណុចមួយទៀត ពាក់ព័ន្ធនឹងអង្គច្បាប់ ឃើញថាគាត់បានយកមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានលក្ខណៈផ្ទុយច្បាប់ទាំងស្រុង ។ ចំណុចទី៣ ការអះអាងរបស់ដើមចោទ សុំលុបឬសុំមិនឲ្យអនុញ្ញាតអនុវត្តលើដីកាសម្រេចទាំងមូល គឺគាត់អត់មានសិទ្ធិតែម្ដង ដោយមិនមានប៉ះពាល់ដល់កម្មសិទ្ធិរបស់គាត់នោះទេ ។ តែអ្វីដែលគាត់មិនបានប៉ះពាល់ដល់កម្មសិទ្ធិរបស់គាត់ តែគាត់ប្ដឹង ។

- លោកមេធាវី [redacted] បានធ្វើសេចក្ដីថ្លែងការណ៍តបថាខ្លួនសុំបញ្ជាក់ជូនលោកចៅក្រមថា ទម្រង់នៃពាក្យសុំដីកាសម្រេចនេះ មានទម្រង់និងនីតិវិធីត្រឹមត្រូវ ។ អ៊ីចឹង នីតិវិធីដែលមិនមែនដីកាសម្រេចមិនចាំបាច់ឲ្យមានភាគីម្ខាងទៀតទេ ។ មួយវិញទៀត ទាក់ទងនឹងការប្ដឹងនេះ ធ្វើឡើងឲ្យស្របទៅតាមផ្លូវច្បាប់នោះទេ ដោយមុនប្ដឹង ភាគីបានព្រមព្រៀងគ្នាអស់ហើយ ដូច្នេះតាមច្បាប់គេត្រូវធ្វើតាមនីតិវិធីមិនមែនជាបណ្ដឹងក្នុងរឿងមត៌ក ។

៣-៣ **ការទាញហេតុផលចុងក្រោយ**

លោកមេធាវី [redacted] បានធ្វើការទាញហេតុផលចុងក្រោយថានៅក្នុងរឿងនេះ មានកំណត់ចំណុចវិវាទចំនួន២ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយទី១- តើការទាមទាររបស់ដើមចោទមិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តសៀមរាប និងការទាមទាររបស់ដើមចោទឲ្យលុបចោលដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មានភាពត្រឹមត្រូវដែរឬទេ ? ខ្លួនបានលើកហេតុផលជម្រាបជូនលោកចៅក្រមហើយថាដើមចោទពិតជាមានភាពត្រឹមត្រូវស្របទៅតាមមាត្រា **៣៥៦** នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា **១១៥៦** នៃក្រមរដ្ឋប្បវេណី ទាក់ទងសន្តតិជន ។ ទី២ ទាក់ទងនឹងការទាមទារសំណងជំងឺចិត្ត ដោយសារហេតុផលរបស់ចុងចម្លើយ គាត់មានគំនិតទុច្ចរិត គាត់បានដឹងហើយថាទ្រព្យនោះជាទ្រព្យរបស់មតកជនឈ្មោះ [redacted] ហើយឈ្មោះ [redacted] នេះមានសន្តតិជនផ្សេង ហើយគាត់បានដឹងហើយថាមានសំណុំរឿងផ្សេង សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ៦៦ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ តុលាការកំពុងដំណើរការ គាត់បែរជាមានគំនិតទុច្ចរិត ដាក់ពាក្យសុំដីកាសម្រេចយកទ្រព្យនោះ ។ អ៊ីចឹង កំហុសទាំងអស់នេះ គឺជាកំហុសរបស់ចុងចម្លើយ ហេតុនេះចុងចម្លើយត្រូវសងសំណងការខូចខាតដល់ដើមចោទ ។ ខ្លួនសុំបញ្ជាក់បន្ថែមថាគំនិតទុច្ចរិត ចង់និយាយថា គាត់បានដឹងហើយបែរជាបំពាន នេះហៅគំនិតទុច្ចរិត ។ ទាក់ទងគាត់លើកឡើងថាភាគីខាងខ្លួនមានគំនិតទុច្ចរិត នៅក្រៅផ្លូវច្បាប់បែរជាប្តឹងមកតុលាការទាមទារទ្រព្យនេះ គឺថាគាត់ជាសន្តតិជនស្របច្បាប់ គាត់មានឯកសារដែលទទួលស្គាល់ដោយអាជ្ញាធរគឺជាកូនរបស់មតកជនឈ្មោះ [redacted] **ចាន់ឌី** យ៉ាងពិតប្រាកដ ។

លោកមេធាវី [redacted] បានធ្វើការទាញហេតុផលចុងក្រោយថាដូចខ្លួនបានបញ្ជាក់រួចហើយថា បញ្ហានេះពាក់ព័ន្ធនឹងបញ្ហាច្បាប់ បញ្ហាសិទ្ធិ តើមានភាពត្រឹមត្រូវដែរឬទេ? ខ្លួននៅតែសុំរក្សាការថ្លែងការណ៍ដដែល ។ ប៉ុន្តែពាក់ព័ន្ធនឹងការលើកឡើងរបស់លោកមេធាវីថាភាគីខាងចុងចម្លើយមានគំនិតទុច្ចរិតហើយ បញ្ហានេះគួរតែខាងខ្លួនជាអ្នកលើកឡើងទេ ហើយខាងខ្លួនក៏មិនហ៊ានប្រើពាក្យនេះ ហើយមិនគួរប្រើពាក្យនេះ ។ គំនិតទុច្ចរិត ខាងណាមានគំនិតទុច្ចរិត ដែលខ្លួនឯងជាអ្នកប្តឹងរំខានគេ ចង់បានទ្រព្យគេ ហើយសួរថាមានគំនិតទុច្ចឬអត់ ? នេះខាងខ្លួនមិនដែលនិយាយទេ តែភាគីខាងគាត់លើកឡើងដដែល យើងមិនគួរលើកឡើងអំពីគំនិតទុច្ចរិតនោះទេ ។ ផ្ទុយទៅវិញ ភាគីខាងគាត់ពុំមានពាក់ព័ន្ធអ្វីសោះ ដែលប្តីគេនិងជាប្រពន្ធពេញច្បាប់និងមានកូនស្របច្បាប់ ទៅជាគាត់ថាខាងខ្លួនមានគំនិតទុច្ចរិត តែខាងគាត់ទៅវិញទេដែលមានគំនិតទុច្ចរិត ។ ខ្លួនសូមបញ្ជាក់ថាបើសិនជាចុងចម្លើយមានគំនិតទុច្ចរិតដូចការលើកឡើងរបស់ដើមចោទ គឺគាត់មិនដាក់ពាក្យប្តឹងសុំមកតុលាការនោះទេ ។

## **សំអាងហេតុ**

ផ្អែកតាមលទ្ធផលនៃការសាកសួរ និងការពិនិត្យភស្តុតាងនានាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា ៖

១- ពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ របស់លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] (តតិយជន) ធ្វើឡើងត្រឹមត្រូវច្បាប់ តុលាការអាច



Scanned with CamScanner

ទទួលមកវិនិច្ឆ័យនិងសម្រេចសេចក្តីបាន ស្របតាមបញ្ញត្តិមាត្រា ៧ មាត្រា ៨ និងមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២- អំពីការទាមទារ មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ៖

២-១ ភាគីដើមចោទបានអះអាងថា ខ្លួនប្តឹងទាមទារនេះ គឺដោយសារតែភាគីខាងខ្លួន([redacted] **ចាន់សល្យ**) មានទំនាក់ទំនងជាមួយឈ្មោះ [redacted] **ចាន់នី** នៅអំឡុងឆ្នាំ២០០៥ ជាអនីតិសង្វាស ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយលុះរហូតដល់ឆ្នាំ២០១២ ក៏មានកូនម្នាក់ឈ្មោះ [redacted] **អម្រឹត** ភេទប្រុស កើតនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១២ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៤/២០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ និងឆ្នាំ២០១៦ មានកូនម្នាក់ទៀតឈ្មោះ [redacted] **អមរា** ភេទស្រី កើតថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ មានសំបុត្របញ្ជាក់កំណើតលេខ ៣២៥ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ។ លុះនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០២១ ឈ្មោះ [redacted] **ចាន់នី** ជាឪពុករបស់កូនទាំងពីរបានទទួលមរណភាព ហើយដើមចោទបានដាក់ពាក្យសុំដើម្បីបែងចែកមត៌ក ដែលមាននៅក្នុងសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ **៦៦** ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ។ ខណៈពេលដែលតុលាការកំពុងដំណើរការនីតិវិធី ស្រាប់តែភាគីចុងចម្លើយបានដាក់ពាក្យសុំដីកាសម្រេចជាឯកតោភាគី នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ដែលបានបង្កើតជាសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមួយទៀត គឺលេខ **១៤៦** ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដែលមានកម្មវត្ថុនិងទ្រព្យសម្បត្តិមត៌ក គឺដូចគ្នា ហើយបន្ទាប់មក សាលាដំបូងខេត្តសៀមរាបបានចេញដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ដោយបានសម្រេចប្រគល់មត៌ករបស់មតកជនឈ្មោះ [redacted] **ចាន់នី** ទាំងអស់ឱ្យទៅចុងចម្លើយ ដែលការចេញដីកាសម្រេចប្រគល់នេះគឺធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន ដែលជាសន្តតិជនឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ។ ការអះអាងនេះមានសង្គតិភាពជាមួយសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៤ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ (របស់ឈ្មោះ [redacted] **អម្រឹត**), សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៥ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ (របស់ឈ្មោះ [redacted] **អមរា**), សេចក្តីចម្លងសំបុត្រមរណភាព ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានសំបុត្រមរណភាពលេខ ១៤៣ សៀវភៅមរណភាពលេខ ០៦/២០២១ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] **ចាន់នី អ៊ែននី**, ដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២, ឯកសារសំណុំរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ **៦៦** ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប និងឯកសារសំណុំរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ **១៤៦** ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ។

២-២ ការអះអាងនូវការទាមទាររបស់ភាគីដើមចោទនេះ ត្រូវបានភាគីចុងចម្លើយបដិសេធ ដោយភាគីចុងចម្លើយបានអះអាងតបថា ការទាមទាររបស់ភាគីដើមចោទត្រង់ចំណុចទី១នេះ មិនមានភាពត្រឹមត្រូវតាមច្បាប់នោះទេ ដោយហេតុថាកូនទាំងពីរ គឺឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** របស់ដើមចោទដែលតំណាងដោយដើមចោទនេះ ពុំមានសិទ្ធិតាមផ្លូវដែលទទួលស្គាល់ជាសន្តតិជនរបស់មតកជនឈ្មោះ

[redacted] ចាន់ឌី អ៊ើនឌី ([redacted] ចាន់ឌី) ពីព្រោះមតកជនឈ្មោះ [redacted] ចាន់ឌី បានស្លាប់មុនពេលមានការចុះសំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] អម្រឹត និងឈ្មោះ [redacted] អមរា ។ ហេតុនេះ មិនមានទម្រង់ណាមួយតាមច្បាប់ដែលត្រូវទទួលស្គាល់ឈ្មោះ [redacted] អម្រឹត និងឈ្មោះ [redacted] អមរា ជាកូនរបស់មតកជនឈ្មោះ [redacted] ចាន់ឌី ឡើយ និងហេតុដូច្នេះ ការចេញដីកាសម្រេចលេខ **២៥៧/២០២២** ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប គឺមានភាពត្រឹមត្រូវ ។

**២-៣** ឃើញថា តាមការពិនិត្យលើសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៤ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ (របស់ឈ្មោះ [redacted] **អម្រឹត**) និងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៣២៥ សៀវភៅបញ្ជាក់កំណើត លេខ ០៤/២០២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ (របស់ឈ្មោះ [redacted] **អមរា**) បានបង្ហាញថា ពិតជាមានសរសេរឈ្មោះ [redacted] **ចាន់ឌី** ជាឪពុករបស់ឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ប្រាកដមែន ។ បន្ថែមពីនេះទៀត តាមការពិនិត្យលើសេចក្តីចម្លងសំបុត្រមរណភាព ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានសំបុត្រមរណភាពលេខ ១៤៣ សៀវភៅមរណភាពលេខ ០៦/២០២១ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] **ចាន់ឌី អ៊ើនឌី** បានបង្ហាញថាឈ្មោះ [redacted] **ចាន់ឌី** ឬ [redacted] **ចាន់ឌី អ៊ើនឌី** ពិតជាបានស្លាប់នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រាកដមែន ។ ត្រង់នេះ តុលាការពិនិត្យឃើញថា ឈ្មោះ [redacted] **ចាន់ឌី** ឬ [redacted] **ចាន់ឌី អ៊ើនឌី** ពិតជាបានស្លាប់ មុនកាលបរិច្ឆេទនៃការចុះក្នុងសំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ប្រាកដមែន ។

**២-៤** ឈ្មោះ [redacted] **ចាន់ឌី** និងឈ្មោះ [redacted] **ចាន់សល្យ** បានបង្កើតទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយភាគីឈ្មោះ [redacted] **ចាន់សល្យ** បានអះអាងថាខ្លួននិងឈ្មោះ [redacted] **ចាន់ឌី** បានបង្កើតបានកូនចំនួន២នាក់ គឺឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ។ ត្រង់នេះ តុលាការយល់ឃើញថា អានុភាពនៃការបង្កើតទំនាក់ទំនងបុត្តភាពនិងបិតុភាពរវាងឈ្មោះ [redacted] **ចាន់ឌី** និងឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ដែលជាកូន គឺត្រូវធ្វើតាមការទទួលស្គាល់ ដែលអាចជាការទទួលស្គាល់ដោយស្ម័គ្រឬតាមការទាមទារឱ្យទទួលស្គាល់ និងតាមទម្រង់ដែលច្បាប់បានកំណត់ ស្របតាមបញ្ញត្តិមាត្រា ៩៩៣ មាត្រា ៩៩៧ មាត្រា ៩៩៨ និងមាត្រា ១០០១ នៃក្រមរដ្ឋប្បវេណី ។

**២-៥** មិនមានភស្តុតាងណាមួយក្នុងសំណុំរឿង អាចបង្ហាញឱ្យតុលាការឃើញនិងជឿបានឈ្មោះ [redacted] **ចាន់ឌី អ៊ើនឌី** ឬ [redacted] **ចាន់ឌី** បានជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ឬបានស្នើសុំចុះកំណើតកូនឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ហើយបានចុះហត្ថលេខា ឬផ្តិតមេដៃ នៅក្នុងសំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ឬសេចក្តីសម្រេចរបស់តុលាការដែលបានសម្រេចឱ្យទទួលស្គាល់ឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ជាកូនរបស់ឈ្មោះ [redacted] **ចាន់ឌី អ៊ើនឌី** ឬ [redacted] **ចាន់ឌី** នោះទេ ។

**២-៦** ឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** មិនមានសិទ្ធិតាមច្បាប់លើទ្រព្យសម្បត្តិដែលជាមត៌ករបស់មតកជនឈ្មោះ [redacted] **ចាន់ឌី អ៊ើនឌី** ឬ [redacted] **ចាន់ឌី** ដែលជាកម្មវត្ថុនៃការប្តឹងទាមទារក្នុងសំណុំរឿងនេះទេ និងហេតុដូច្នេះ ការធ្វើបណ្តឹងតវ៉ារបស់តតិយជនដោយភាគីដើមចោទឈ្មោះ [redacted] **ចាន់សល្យ** ដែលជាអ្នកមានអំណាចមេបាលើឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ក្នុងការទាមទារមិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប មិនមានហេតុផលត្រឹមត្រូវនោះទេ ។ ផ្ទុយទៅវិញ ការអះអាងតបរបស់ភាគីចុងចម្លើយ

មានហេតុផលត្រឹមត្រូវ ។ ហេតុដូច្នេះ តុលាការគប្បីសម្រេចច្រានចោលនូវការទាមទាររបស់ភាគីដើមចោទត្រង់ចំណុចនេះ ។

៣- អំពីការទាមទារ ឱ្យលុបចោលដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តសៀមរាប ៖

៣-១ ដើមចោទបានទាមទារឱ្យលុបចោលដីកាសម្រេចលេខ ២៥៧/២០២២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដោយអះអាងថាការចេញដីកាសម្រេចនេះ គឺធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន ដែលជាសន្តតិជនឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ដែលត្រូវទទួលមត៌ករបស់មតកជនឈ្មោះ [redacted] **ចាន់នី** ហើយចុងចម្លើយមានចេតនាទុច្ចរិតក្នុងដាក់ពាក្យសុំឱ្យចេញដីកាសម្រេចនេះ ។ ការទាមទារនេះត្រូវបានភាគីចុងចម្លើយបដិសេធ ដោយអះអាងតបថាក្នុងការលុបដីកាសម្រេចនេះ តម្រូវឱ្យមាននីតិវិធីច្បាប់កំណត់ច្បាស់ និងកំណត់អ្នកមានសិទ្ធិសុំលុប ។ ដីកាសម្រេចនេះគឺជាការសម្រេចអំពីទំនាក់ទំនងសិទ្ធិជាផ្លូវច្បាប់និងប្រយោជន៍ស្របច្បាប់ និងចំណងទាក់ទងរបស់ចុងចម្លើយជាមួយកូនបង្កើតរបស់ខ្លួន ដែលមានការពាក់ព័ន្ធនឹងមតកជនឈ្មោះ [redacted] **ចាន់នី អ៊ើននី** តែប៉ុណ្ណោះ និងហេតុនេះដីកាសម្រេចនេះ តាមច្បាប់ គឺមានតែភាគីក្នុងដីកាសម្រេចនេះទេ ដែលមានសិទ្ធិសុំលុបបាន ។ ដោយឡែក តតិយជនមិនមានសិទ្ធិមកធ្វើការប្តឹងលុបដីកានេះបានឡើយ ។

៣-២ ឃើញថា តាមមូលដ្ឋាន និងសំអាងហេតុក្នុងចំណុច ២ ខាងលើ បានបង្ហាញថាឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** ដែលតំណាងដោយភាគីដើមចោទ មិនមានសិទ្ធិតាមផ្លូវច្បាប់លើទ្រព្យសម្បត្តិដែលជាមត៌ក របស់មតកជនឈ្មោះ [redacted] **ចាន់នី អ៊ើននី** ឬ [redacted] **ចាន់នី** ដែលជាកម្មវត្ថុនៃការទាមទារនោះទេ និងហេតុដូច្នេះ ការទាមទាររបស់ភាគីដើមចោទ ក្នុងការឱ្យលុបចោលដីកាសម្រេច ២៥៧/២០២២ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចចាត់ចែងមត៌កនេះ មិនមានភាពត្រឹមត្រូវនោះដែរ ។ ផ្ទុយទៅវិញ ការអះអាងតបរបស់ភាគីចុងចម្លើយក្នុងការបដិសេធនូវការទាមទារនេះ មានហេតុផលត្រឹមត្រូវ តាមមូលដ្ឋាននីតិវិធី និងសារជាតុ ។

៤- អំពីការទាមទារ ឱ្យចុងចម្លើយសងសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០.០០០ (មួយរយលាន)រៀល ឱ្យមកដើមចោទ ៖

៤-១ ភាគីដើមចោទបានទាមទារឱ្យចុងចម្លើយសងសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០.០០០(មួយរយលាន)រៀល ឱ្យមកខ្លួន ដោយអះអាងថាភាគីចុងចម្លើយមានគំនិតទុច្ចរិត ដែលបានដឹងហើយថាឈ្មោះ [redacted] **អម្រឹត** និងឈ្មោះ [redacted] **អមរា** គឺជាសន្តតិជនរបស់ឈ្មោះ [redacted] **ចាន់នី អ៊ើននី** ឬ [redacted] **ចាន់នី** និងត្រូវទទួលមត៌ករបស់ឈ្មោះ [redacted] **ចាន់នី អ៊ើននី** ឬ [redacted] **ចាន់នី** ហើយបែរជាមកដាក់ពាក្យសុំដីកាសម្រេចបែងចែកមត៌កជាឯកតោភាគី ទាំងបំភាន់ និងដោយបំពាន ។ ការទាមទារនិងការអះអាងនូវការទាមទារនេះ ត្រូវបានភាគីចុងចម្លើយបដិសេធ ដោយអះអាងតបថាភាគីខាងខ្លួនមិនមានគំនិតទុច្ចរិតអីនោះទេ ហើយក៏គ្មានកំហុសដែរ ។

៤-២ តាមសំអាងហេតុទី២ និងសំអាងហេតុទី៣ ខាងលើ *ឃើញថា* ការទាមទារចម្បងនៃពាក្យបណ្តឹងរបស់ភាគីដើមចោទត្រូវបានតុលាការសម្រេចច្រានចោលហើយ និងហេតុនេះ ការទាមទារនូវសំណងការខូចខាត និងជំងឺចិត្តចំនួន ១០០.០០០.០០០(មួយរយលាន)រៀល ពីភាគីចុងចម្លើយ ក៏មិនមាន



Scanned with CamScanner

ហេតុផលត្រឹមត្រូវដែរ ។ លើសពីនេះទៀត មិនមានភស្តុតាងណាមួយក្នុងសំណុំរឿង បានបង្ហាញឱ្យឃើញពីកំហុសរបស់ភាគីចុងចម្លើយ និងទំហំនៃព្យសនកម្មជាក់ស្តែងដែលបានកើតឡើងចំពោះភាគីដើមចោទនោះដែរ ។ ហេតុដូចនេះ តុលាការគប្បីសម្រេចច្រានចោលនូវការទាមទារនេះផងដែរ ។

៥- គប្បីឱ្យភាគីដើមចោទ ទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**សេចក្តីសម្រេចបញ្ចប់**

១- ច្រានចោលគ្រប់ចំណុចនៃការទាមទារទាំងអស់ ក្នុងពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ របស់លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

២- ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ភាគីដើមចោទ ។

សាលក្រមនេះ គូភាគីអាចប្តឹងឧទ្ធរណ៍តាមមាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រម**
ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ខេត្តសៀមរាប ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២២
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រម**
[redacted]